**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៤២៤ ប្រក.កសក

# ប្រកាស

## ស្តីពី

## សោហ៊ុយសេវាចុះបញ្ជិកា និង បញ្ជិកាជាថ្មី លើសម្ភារៈកសិកម្ម

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីបមាណី និងការគ្រប់គ្រងសម្ភារៈកសិកម្ម
- បានឃើញសារាចរណែនាំលេខ៣៤៥ សរណន.កសក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០២ ស្តីពីការអនុវត្តអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីបមាណី និងការគ្រប់គ្រងសម្ភារៈកសិកម្ម
- តាមសំណើរបស់នាយកដ្ឋាននីតិកម្មកសិកម្ម

## ស ម្រេ ច

**ប្រការ ១** : កំណត់សោហ៊ុយសេវាចុះបញ្ជិកា និង បញ្ជិកាជាថ្មី ចំនួនមួយរយហាសិបពាន់រៀលគត់ (១៥០.០០០៛) សម្រាប់សម្ភារៈកសិកម្មមួយមុខ។

**ប្រការ ២** : ប្រាក់ចំណូលពីសោហ៊ុយសេវាចុះបញ្ជិកា និង បញ្ជិកាជាថ្មី ត្រូវបង់ចូលថវិកាជាតិ ។

**ប្រការ ៣** : សេចក្តីសម្រេច និង ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤** : អគ្គនាយកក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ- ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាន ផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ បណ្តានាយកដ្ឋានដែលស្ថិតនៅក្រោមឪវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គ្រប់ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែ ៥ ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ចិន្ត្រ. ណារុន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៤
- ឯកសារ- កាលប្បវត្តិ